# កំណត់ហេតុអង្គប្រជុំ

## សិក្ខាសាលាផ្សព្វផ្សាយកញ្ចប់ព័ត៌មានដេញថ្លៃជាសាធារណៈជ្រើសរើសអ្នកផ្តល់សេវាផ្គត់ផ្គង់ទឹកស្អាត ចំនួន ៣ទីតាំង ស្ថិតក្នុងខេត្តសៀមរាប ខេត្តរតនគិរី និងខេត្តឧត្តរមានជ័យ នៅទីស្តីការក្រសួង នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៦ វេលាម៉ោង៨:៣០ នាទីព្រឹក

១) សមាសភាពចូលរួម

- ឯកឧត្តម តន់ សុខជា — អគ្គនាយកទឹកស្អាត
- លោក ចាន់ ពុទ្ធារក្ស — ប្រធាន នាយកដ្ឋានស្តីទីបញ្ញត្តកម្មទឹកស្អាត
- លោក សឿង យុត្តិរ៉ា — អនុប្រធាន នាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត
- លោក នី ស្រស់ — ប្រធានការិយាល័យ នៃនាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត
- លោក ជឹម ស៊ីដែន — អនុប្រធានការិយាល័យ នៃនាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត
- លោក ថេង សុផានិត — មន្ត្រី នៃនាយកដ្ឋានបញ្ញត្តកម្មទឹកស្អាត
- លោក ហឿន រតនៈ — អ្នកសម្របសម្រួលផ្នែកហេដ្ឋារចនាសម្ព័ន្ធ នៃកម្មវិធី CAPRED
- លោក កាំង ស៊ីញលី — អ្នកគ្រប់គ្រងវិនិយោគ នៃកម្មវិធី CAPRED
- លោក លុន សំបូរ — ទីប្រឹក្សាបច្ចេកទេស នៃកម្មវិធី CAPRED
- លោក ហ៊ឹង ហុង — ម្ចាស់ស្ថានីយទឹកស្អាតពន្លៃ ទានកាំ
- លោក ទឹង និវត្តន៍ — ម្ចាស់ស្ថានីយទឹកស្អាតឃុំព្រៃជ្រូក
- លោក ឯម សុទិព្វផល្លី — ម្ចាស់ស្ថានីយទឹកស្អាតស្វាយជ្រះ
- លោក ឡេា ស៊ីម៉េង — តំណាងស្ថានីយទឹកស្អាតភ្នំលៀប
- លោក ម៉ី ស៊ីផល — តំណាងស្ថានីយទឹកស្អាតកោះញែក
- លោក ហោ ឃីកេង — ទីប្រឹក្សា
- លោក អោក វ៉ាន់ដា — មន្ត្រីធនាគារ FTB

- លោក ប៉ា ដេប៉ាក់ តំណាងក្រុមហ៊ុន TEM Trading ផ្នែកលក់ម៉ូទ័រ
- លោក ចេង វិសាល វិស្វករ
- សុធានី រចនា តំណាងក្រុមហ៊ុន Luma System
- មួង មីនា តំណាងក្រុមហ៊ុន Luma System

## ២) ព័ត៌មានថ្មីៗបន្ថែម

- យោងតាមប្រសាសន៍របស់ ឯកឧត្តម តន់ សុខជា ជាប្រធានអង្គប្រជុំ បានសម្រេចធ្វើការផ្លាស់ប្តូរពេលវេលាបើកសំណើដេញថ្លៃ ទៅវេលាម៉ោង ១០:០០ នាទីព្រឹក នាថ្ងៃទី១៧ ខែមីនា ឆ្នាំ២០២៦។
- ក្រុមការងារកម្មវិធី CAPRED នឹងធ្វើការផ្សព្វផ្សាយឯកសារបន្ថែមទៅក្នុងគេហទំព័រ CAPRED និង Bong Thom រួមមាន៖
    - បទបង្ហាញស្តីពីកញ្ចប់ដេញថ្លៃ និង ដំណើរការដេញថ្លៃ ដែលបានបង្ហាញក្នុងសិក្ខាសាលា
    - កំណត់ហេតុអង្គប្រជុំ
    - គំរូកិច្ចព្រមព្រៀងផ្តល់ជំនួយរវាងកម្មវិធី CAPRED និងអ្នកឈ្នះការដេញថ្លៃ

## ៣) សំណួរ-ចម្លើយ

| លរ | សំណួរ | ចម្លើយ |
|---|---|---|
| ១ | តើកាលបរិច្ឆេទ និងម៉ោងឈប់ទទួលឯកសារដេញថ្លៃនៅពេលណា? | ការបើកសំណើដេញថ្លៃនឹងប្រព្រឹត្តទៅនៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២៦ វេលាម៉ោង ១០:០០ នាទីព្រឹក (ដោយមានការកែ មកម៉ោង ១០:០០ នាទីព្រឹក ដើម្បីបង្កលក្ខណៈងាយស្រួល)។ |
| ២ | តើសំណើដេញថ្លៃដែលមានភាពពេញលេញត្រូវមានធាតុផ្សំអ្វីខ្លះ? | ត្រូវមានចំណុចសំខាន់ ៣ គឺ៖ ១. ប្រាក់កក់ធានា ចំនួន ៥,០០០ ដុល្លារ ដែលមានការធានាពីធនាគារ ២. សំណើបច្ចេកទេស និង ៣. សំណើហិរញ្ញវត្ថុ។ |
| ៣ | តើលក្ខណៈវិនិច្ឆ័យចម្បងក្នុងការជ្រើសរើសអ្នកឈ្នះគឺជាអ្វី? | គណៈកម្មការនឹងពិនិត្យវាយតម្លៃទៅលើសមត្ថភាពបច្ចេកទេស មុននឹងឈានទៅដល់ |

| | | |
|---|---|---|
| | | ការពិនិត្យលើសំណើហិរញ្ញវត្ថុ។ ក្រៅពីសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុ គណៈកម្មការផ្តោតសំខាន់លើ ចំនួនបណ្តាញតភ្ជាប់ដែលអ្នកដេញថ្លៃផ្តល់ជូនដល់អ្នកប្រើប្រាស់ដោយឥតគិតថ្លៃ ក្នុងរយៈពេល ១២ ខែដំបូង។ អ្នកដែលផ្តល់ចំនួនតភ្ជាប់ឥតគិតថ្លៃច្រើនជាងគេនឹងទទួលបានចំណាត់ថ្នាក់ខ្ពស់។ |
| ៤ | តើការបង្ហាញសមត្ថភាពហិរញ្ញវត្ថុបែបណាដែលគណៈកម្មការជឿជាក់? | គណៈកម្មការចង់ឃើញ របាយការណ៍ធនាគារ (Bank Statement) រយៈពេល ១២ ខែចុងក្រោយ ដើម្បីមើលពីចរន្តសាច់ប្រាក់ពិតប្រាកដ ។ ការដាក់ប្រាក់ចូលក្នុងគណនីភ្លាមៗក្នុងចំនួនច្រើន មុនថ្ងៃដេញថ្លៃនឹងមិនត្រូវបានជឿជាក់ឡើយ។ |
| ៥ | តើទ្រព្យសកម្មរបស់អាជីវកម្មទឹកស្អាត ដែលរួមមានហេដ្ឋារចនាសម្ព័ន្ធ និងលំហូរសាច់ប្រាក់របស់អាជីវកម្ម អាចប្រើសម្រាប់បង្ហាញសមត្ថភាពហិរញ្ញវត្ថុបានដែរឬទេ? | អាចបង្ហាញបាន ប៉ុន្តែក្នុងលក្ខខណ្ឌដូចទៅនឹងធនធានអចលនទ្រព្យដែរ ដែលអ្នកដេញថ្លៃត្រូវបញ្ជាក់ថាទ្រព្យសកម្មរបស់អាជីវកម្មទឹកស្អាតនេះត្រូវបានដាក់ជាទ្រព្យបញ្ចាំហើយ ឬនៅ។ |
| ៦ | ហេតុអ្វីបានជាត្រូវចេញអាជ្ញាប័ណ្ណដាច់ដោយឡែកពីគ្នា ទោះបីជាតំបន់នៅក្បែរគ្នា? | ការតម្រូវឲ្យមានអាជ្ញាប័ណ្ណដាច់ដោយឡែកពីគ្នា ព្រោះប្រព័ន្ធនីមួយៗមិនជាប់គ្នា ក្នុងន័យថាប្រព័ន្ធនីមួយៗអាចមានប្រភពទឹកផ្សេងគ្នា និងការចំណាយប្រតិបត្តិការផ្សេងគ្នាផងដែរ។ ម្យ៉ាងទៀត ដើម្បីងាយស្រួលក្នុងការគ្រប់គ្រងផ្លូវច្បាប់ ប្រសិនបើមានបញ្ហានៅប្រព័ន្ធណាមួយ ក្រសួងអាចចាត់វិធានការតែលើអាជ្ញាប័ណ្ណប្រព័ន្ធនោះ ។ |
| ៧ | តើអ្នកដែលគ្មានបទពិសោធន៍ផ្ទាល់ក្នុងវិស័យទឹកស្អាតអាចចូលរួមបានទេ? | អាចចូលរួមបាន ប៉ុន្តែត្រូវភ្ជាប់មកជាមួយនូវប្រវត្តិរូប (CV) ដែលបង្ហាញពីបទពិសោធន៍បច្ចេកទេសពាក់ព័ន្ធផ្សេងទៀត ឬបង្ហាញពី |

| | | |
|---|---|---|
| | | ក្រុមការងារដែលមានសមត្ថភាព ដើម្បីឱ្យគណៈកម្មការវាយតម្លៃមានទំនុកចិត្ត។ |
| ៨ | តើអ្នកដែលមានបទពិសោធន៍ផ្ទាល់ ប៉ុន្តែមិនមានឈ្មោះក្នុងអាជ្ញាប័ណ្ណ(ករណីជាអាជីវកម្មបែបគ្រួសារ) តើគួរបំពេញសំណើដេញថ្លៃបែបណា? | អ្នកដេញថ្លៃអាចបញ្ជាក់ពីភាគរយនៃកម្មសិទ្ធិរបស់ខ្លួនក្នុងអាជីវកម្មនីមួយៗ ឬបំពេញឈ្មោះដែលមាននៅលើអាជ្ញាប័ណ្ណជាអ្នកចូលរួមដេញថ្លៃ ដើម្បីបង្កលក្ខណៈងាយស្រួលឲ្យគណៈកម្មការធ្វើការវាយតម្លៃ។ |
| ៩ | ប្រសិនបើមានការចូលភាគហ៊ុនគ្នាក្នុងការដាក់ដេញថ្លៃ តើអ្នកដេញថ្លៃត្រូវបំពេញសំណើដេញថ្លៃយ៉ាងដូចម្តេច? | អ្នកដេញថ្លៃត្រូវបំពេញឈ្មោះ និងព័ត៌មានរបស់ម្ចាស់ភាគហ៊ុនទាំងអស់ និងបញ្ជាក់ពីម្ចាស់កម្មសិទ្ធិនៃទ្រព្យសម្បត្តិនីមួយៗទាំងអស់ដែលបានបង្ហាញនៅក្នុងសំណើហិរញ្ញវត្ថុ។ អ្នកដេញថ្លៃក៏អាចភ្ជាប់មកជាមួយនូវលិខិតបញ្ជាក់ពីភាគហ៊ុនរបស់បុគ្គលនីមួយៗ ប្រសិនបើមាន។ |
| ១០ | តើមានបុគ្គលណាខ្លះដែលត្រូវបានហាមឃាត់មិនឱ្យចូលរួម ក្នុងករណីដែលមានទំនាស់ផលប្រយោជន៍ (Conflict of Interest)? | មន្ត្រីក្រសួងដែលគ្រប់គ្រងវិស័យទឹកស្អាត និងសមាជិកគ្រួសារ (ឪពុកម្តាយ បងប្អូន) របស់អ្នកដែលមានការពាក់ព័ន្ធក្នុងការរៀបចំ ឬវាយតម្លៃការដេញថ្លៃ មិនត្រូវបានអនុញ្ញាតឱ្យចូលរួមឡើយ។ |
| ១១ | តើអ្នកដេញថ្លៃម្នាក់អាចដេញថ្លៃលើសពីមួយកញ្ចប់បានដែរឬទេ? | បាន ប៉ុន្តែអ្នកដេញថ្លៃត្រូវបង្ហាញភស្តុតាងថាខ្លួនមានសមត្ថភាពហិរញ្ញវត្ថុ និងបច្ចេកទេសគ្រប់គ្រាន់សម្រាប់គ្រប់គ្រងកញ្ចប់ទាំងនោះក្នុងពេលតែមួយ។ |
| ១២ | តើកម្មវិធី CAPRED ផ្តល់ជំនួយក្នុងលក្ខខណ្ឌបែបណា? | ជំនួយនឹងត្រូវបានផ្តល់ជូនជាដំណាក់កាលបន្ទាប់ពីការសាងសង់ត្រូវបានបញ្ចប់ ស្របតាមបទដ្ឋានបច្ចេកទេសដែលបានព្រមព្រៀងគ្នា។ កម្មវិធីមិនមានការផ្តល់ប្រាក់មុនសម្រាប់ការសាងសង់នោះទេ។ |

| | | |
|---|---|---|
| ១៣ | តើអ្នកដេញថ្លៃអាចសាងសង់ប្រព័ន្ធដែលមានសមត្ថភាពធំជាងការសិក្សាបានទេ? | បាន ប្រសិនបើអ្នកដេញថ្លៃមានទស្សនវិស័យវែងឆ្ងាយ ប៉ុន្តែទឹកប្រាក់ជំនួយពី CAPRED គឺត្រូវបានកំណត់ថេរ មិនកើនឡើងតាមទំហំវិនិយោគដែលអ្នកដេញថ្លៃដាក់បន្ថែមនោះទេ។ |
| ១៤ | តើចំនួនបណ្តាញតភ្ជាប់ដែលអ្នកដេញថ្លៃផ្តល់ជូនដល់អ្នកប្រើប្រាស់ដោយឥតគិតថ្លៃ គិតរួមទាំងតំណសម្រាប់គ្រួសារដែលមានប័ណ្ណសមធម៌ដែរឬទេ? | ចំនួនបណ្តាញតភ្ជាប់ដែលអ្នកដេញថ្លៃផ្តល់ជូនដល់អ្នកប្រើប្រាស់ដោយឥតគិតថ្លៃ គិតរួមទាំងតំណសម្រាប់គ្រួសារដែលមានប័ណ្ណសមធម៌ តំណសម្រាប់គ្រួសារមិនមានប័ណ្ណសមធម៌ តំណសម្រាប់គ្រឹះស្ថាន និងអាជីវកម្មផ្សេងៗបាន។ ដោយឡែកសម្រាប់គ្រួសារមានប័ណ្ណសមធម៌ CAPRED នឹងផ្តល់ការឧបត្ថម្ភទុនសម្រាប់តំណប្រភេទនេះ ដល់អ្នកដេញថ្លៃ។ |